# ការកសាងផែនការយុទ្ធសាស្ត្រ

ដោយ ឡេងឆាយ

## ការកសាងផែនការយុទ្ធសាស្ត្រជាអ្វី?

- ជាដំណើរការមួយ ដើម្បីកំនត់នូវអ្វីដែលស្ថាប័នអ្នកចង់បាននាពេលអនាគត ហើយធ្វើការសំរេចចិត្តអំពីវិធីផ្សេងៗ ដើម្បីឈានទៅសំរេចគោលបំណងនោះ។
- ជាដំណើរការស្វែងរក និងកំនត់បញ្ហាយុទ្ធសាស្ត្ររបស់អង្គការ ហើយលើកយុទ្ធសាស្ត្រសមស្របដើម្បីដោះស្រាយ។
- មានន័យលើសពីផែនការរយ:ពេលវែង ដោយសារគេបានពិចារណាទៅលើស្ថានភាព និងលក្ខខណ្ឌប្រែប្រួលនានា នៅពេលធ្វើផែនការ។

## ការកសាងផែនការយុទ្ធសាស្ត្រមានប្រយោជន៍អ្វីខ្លះ?

- សំរាប់អោយអង្គការអាចរស់រានមានជីវិតបាន ក្នុងស្ថានភាពមួយដែលមានការប្រែប្រួល។
- ជួយអោយអង្គការបានគិត និងបញ្ជាក់ពីទិសដៅយុទ្ធសាស្ត្ររបស់ខ្លួន។
- ជួយអង្គការកំនត់ និងដោះស្រាយបញ្ហាយុទ្ធសាស្ត្ររបស់ខ្លួន។
- ជួយអង្គការផ្តោតថាមពល ដោយបុគ្គលិកធ្វើការឆ្ពោះទៅគោលដៅតែមួយ។
- ដំណើរការរបស់វា ជួយកសាងក្រុម ដោយសារបុគ្គលិកភាគច្រើនចូលរួមក្នុងដំណើការកសាងផែនការនេះ។
- អង្គការមានផែនការមេមួយដែលអាចប្រើប្រាស់ដើម្បី៖
  - o ធ្វើជាឧបករណ៍គ្រប់គ្រងដើម្បីធ្វើការងារអោយបានល្អ
  - o ធ្វើជាគ្រោងការណ៍សំរាប់រៀបចំផែនការប្រតិបត្តិការ
  - o ធ្វើជាឧបករណ៍សំរាប់ស្វែងរកមូលនិធិ

This learning article shared by Cambodian Learning Facilitators (www.camlefa.org). All rights reserved.

# ជំហានក្នុងការកសាងផែនការយុទ្ធសាស្ត្រ

## មុនពេលធ្វើផែនការ

ត្រៀមលក្ខណៈ: (លក្ខខណ្ឌយោង រកអ្នក សំរបសំរួល ទីកន្លែង ជំហាន បង្កើតគណៈកម្មការ រៀបវិភាគ ។ល។)

ធ្វើអោយបុគ្គលិកមានការយល់ដឹងពីផែនការ/ដំណើរការ

មើលត្រលប់ក្រោយ: របាយការណ៍វាយតំលៃសិក្ខាសាលាឆ្លុះបញ្ចាំង។

ពិគ្រោះយោបល់ជាមួយអ្នកពាក់ព័ន្ធ (រៀបសំនួរសំភាស/ សួរតាមអ៊ីម៉េល វិភាគទិន្នន័យ រាយការណ៍ពីលទ្ធផលដល់បុគ្គលិក)។

## សិក្ខាសាលាកសាងផែនការ

- វិភាគស្ថានភាព
- វិភាគតំរូវការ
- កំនត់បញ្ហាយុទ្ធសាស្ត្រ (បញ្ហាអភិវឌ្ឍន៍អង្គការ និងបញ្ហាយុទ្ធសាស្ត្រទាក់ទងនឹងកម្មវិធី)
- បង្កើត/កែសំរួល ទស្សនៈវិស័យ បេសកកម្ម គុណតំលៃ។
- បង្កើតគោលបំណងយុទ្ធសាស្ត្រ
- បង្កើតគោលបំណងតាមផ្នែក
- កំនត់សកម្មភាពចំបងៗ និង សូចនាករ។

## លទ្ធផលពីការកសាងផែនការ

- បញ្ចូលលទ្ធផលពីសិក្ខាសាលាទៅក្នុងផែនការពង្រាងមួយ។
- ពិភាក្សា/ទទួលយោបល់ លើពង្រាងផែនការ។
- កែលំអរផែនការ ជាចុងក្រោយ។
- បោះពុម្ពនិងចែកចាយផែនការយុទ្ធសាស្ត្រទៅអ្នកពាក់ព័ន្ធ។

បញ្ជាក់: ដំណើរការកសាងផែនការយុទ្ធសាស្ត្រដែលល្អ ត្រូវធ្វើឡើងក្នុងកំលុងពេលមួយពី៦ទៅ ១២សប្តាហ៍។ ជាទូទៅគេត្រូវការអ្នកសំរបសំរួលម្នាក់ ឬពីរនាក់ ដើម្បីរៀបចំដំណើរការ និងធ្វើការសំរបសំរួលការគិតរបស់បុគ្គលិក។ ការកសាងផែនការយុទ្ធសាស្ត្រជាដំណើរការរៀនសូត្រមួយ។

This learning article shared by Cambodian Learning Facilitators (www.camlefa.org). All rights reserved.